**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងបរិស្ថាន** **ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ** **ក្រសួងមហាផ្ទៃ**

លេខ: ១៩៥ ប្រកប.ស្ក

# ប្រកាសអន្តរក្រសួង

## ស្តីពី

## ការកំណត់កម្រៃអតិបរមានៃសេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ** **ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ** **រដ្ឋមន្ត្រី ក្រសួងបរិស្ថាន**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១១/០១១ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ ៤៨៨អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១០៩អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ១៣៥អនក្រ.បក ចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងបរិស្ថាន
- បានឃើញអនុក្រឹត្យលេខ ៣៦អនក្រ.បក ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការគ្រប់គ្រងសំណល់រឹង
- បានឃើញអនុក្រឹត្យលេខ ១១៣អនក្រ.បក ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៥ ស្តីពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន

## សម្រេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**ប្រការ១.**_

ប្រកាសនេះមានគោលបំណងពង្រឹងប្រតិបត្តិការសេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនប្រកប ដោយតម្លាភាព គណនេយ្យភាព ប្រសិទ្ធភាព និងនិរន្តរភាព សំដៅធានាបានសោភ័ណភាព កិច្ចគាំពារ សុខភាពសាធារណៈ និងបរិស្ថាន។

**ប្រការ២.**_

ប្រកាសនេះមានគោលដៅកំណត់អំពីកម្រៃសេវាអតិបរមា ដើម្បីជាមូលដ្ឋានសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការកំណត់កម្រៃសេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជននៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

**ប្រការ៣.**_

ប្រកាសនេះមានវិសាលភាពសម្រាប់ការអនុវត្តសេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន នៅទូទាំងព្រះរាជាណាចក្រកម្ពុជា។

## ជំពូកទី ២

## កម្រៃអតិបរមានៃសេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន

**ប្រការ៤.**_

កម្រៃសេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន គឺជាកម្រៃដែលរាប់បញ្ចូលនូវកម្រៃសេវាសម្អាត ប្រមូល ដឹកជញ្ជូន និងសេវាទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជន។

**ប្រការ៥.**_

កម្រៃអតិបរមានៃសេវាសម្អាត ប្រមូល ដឹកជញ្ជូន និងសេវាទីលានប្រកបដោយអនាម័យ ត្រូវបានកំណត់ដូចមានចែងនៅក្នុងតារាងឧបសម្ព័ន្ធនៃប្រកាសអន្តរក្រសួងនេះ ។

កម្រៃអតិបរមានៃសេវាទីលានដែលមិនមែនជាទីលានប្រកបដោយអនាម័យ ត្រូវបានកំណត់មិនឱ្យលើស៥០% នៃកម្រៃសេវាទីលានដែលមានចែងនៅក្នុងតារាងឧបសម្ព័ន្ធនៃប្រកាសអន្តរក្រសួងនេះ។

**ប្រការ៦.**_

អនុលោមតាមគោលការណ៍ដូចបានចែងនៅក្នុងមាត្រា៣៣ និង៣៤ នៃអនុក្រឹត្យស្ដីពីការគ្រប់គ្រងសំរាមសំណល់រឹងទីប្រជុំជន រដ្ឋបាលរាជធានី ក្រុង ស្រុក ត្រូវចេញដីកាកំណត់កម្រៃសេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនឱ្យស្របទៅនឹងស្ថានភាពជាក់ស្តែងនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ដោយមិនឱ្យលើសពីកម្រៃអតិបរមាដូចបានកំណត់ក្នុងប្រការ៥ នៃប្រកាសអន្តរក្រសួងនេះឡើយ។

**ប្រការ៧.**_

ក្នុងករណីចាំបាច់ អភិបាលរាជធានី ក្រុង ស្រុកដោយមានការឯកភាពពីក្រុមប្រឹក្សារបស់ខ្លួន អាចលើកសំណើសុំកំណត់កម្រៃសេវាសម្អាត ប្រមូល ដឹកជញ្ជូន និងសេវាទីលានទុកដាក់សំរាម សំណល់រឹងទី

ប្រជុំជន ចំពោះប្រភេទទីតាំងបង្កើតសំណល់ណាមួយ លើសកម្រៃអតិបរមាដែលបានកំណត់ក្នុងតារាងឧបសម្ព័ន្ធនៃប្រកាសអន្តរក្រសួងនេះ ឬចំពោះប្រភេទទីតាំងបង្កើតសំណល់ថ្មីណាមួយដែលមិនមានចែងនៅក្នុងតារាងឧបសម្ព័ន្ធនៃប្រកាសអន្តរក្រសួងនេះ មកក្រសួងមហាផ្ទៃ ដើម្បីពិគ្រោះយោបល់ជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងបរិស្ថាន ដើម្បីពិនិត្យសម្រេច។

## ជំពូកទី ៣
## អន្តរប្បញ្ញត្តិ

**ប្រការ៨._**

កម្រៃសេវាដែលមានចែងក្នុងកិច្ចសន្យាផ្តល់សេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ដែលនៅជាធរមានត្រូវបន្តអនុវត្តរហូតដល់កិច្ចសន្យានោះត្រូវបានកែសម្រួលតាមខ្លឹមសារនៃអនុក្រឹត្យលេខ១១៣ អនក្រ.បក ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៥ ស្តីពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន។

## ជំពូកទី ៤
## អវសានប្បញ្ញត្តិ

**ប្រការ៩._**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសអន្តរក្រសួងនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ១០._**

អគ្គលេខាធិការ អគ្គនាយក អគ្គាធិការ និងប្រធានអង្គភាពចំណុះក្រសួងមហាផ្ទៃ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងបរិស្ថាន ក្រុមប្រឹក្សា និងគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក និងអ្នកពាក់ព័ន្ធនានាត្រូវទទួលបន្ទុកអនុវត្តប្រកាសអន្តរក្រសួងនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ពុធ ៨ រោច ខែ ជេស្ឋ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៦ ខែ មិថុនា ឆ្នាំ២០១៨

| | | |
|---|---|---|
| **ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ** | **ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ** | **រដ្ឋមន្ត្រី ក្រសួងបរិស្ថាន** |
| **សម្តេចក្រឡាហោម ស ខេង** | **អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន** | **សាយ សំអាល់** |

**កន្លែងទទួល៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- អាជ្ញាធរសវនកម្មជាតិ
- អង្គភាពប្រឆាំងអំពើពុករលួយ
- ដូចប្រការ១០
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ឧបសម្ព័ន្ធ

## ភ្ជាប់នឹងប្រកាសអន្តរក្រសួងលេខ ១៩៥ ប្រក.ប.ស្ហ ចុះថ្ងៃទី...៦....ខែមិថុនាឆ្នាំ២០១៨
## ស្តីពីការកំណត់កម្រៃអតិបរមានៃសេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន

| ល.រ | ប្រភេទទីតាំងបង្កើតសំរាម សំណល់រឹងទីប្រជុំជន | កម្រៃអតិបរមានៃសេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| | | ឯកតា | រាជធានីភ្នំពេញ | | | ក្រុង | | | ស្រុក | | |
| | | | សេវាសំអាត ប្រមូល ដឹកជញ្ជូន | សេវាទីលាន | សេវាគ្រប់គ្រង (សរុប) | សេវាសំអាត ប្រមូល ដឹកជញ្ជូន | សេវាទីលាន | សេវាគ្រប់គ្រង (សរុប) | សេវាសំអាត ប្រមូល ដឹកជញ្ជូន | សេវាទីលាន | សេវាគ្រប់គ្រង (សរុប) |
| ១ | ២ | ៣ | ៤ | ៥ | ៦=៤+៥ | ៧ | ៨ | ៩=៧+៨ | ១០ | ១១ | ១២=១០+១១ |
| ក | លំនៅដ្ឋាន | | | | | | | | | | |
| I | លំនៅដ្ឋានរស់នៅធម្មតា | | | | | | | | | | |
| | ១.ផ្ទះល្វែងជាន់ផ្ទាល់ដី | ខែ | ៩ ២០០ | ២ ០០០ | ១១ ២០០ | ៩ ២០០ | ២ ០០០ | ១១ ២០០ | ៧ ៦០០ | ២ ០០០ | ៩ ៦០០ |
| | ២.ផ្ទះល្វែងជាន់ទី១ឡើងទៅ | ខែ | ៦ ០០០ | ២ ០០០ | ៨ ០០០ | ៦ ០០០ | ២ ០០០ | ៨ ០០០ | ៥ ២០០ | ២ ០០០ | ៧ ២០០ |
| | ៣.ផ្ទះដីឡូត៍ធម្មតា | ខែ | ១២ ៤០០ | ២ ៤០០ | ១៤ ៨០០ | ១២ ០០០ | ២ ៤០០ | ១៤ ៤០០ | ៩ ៦០០ | ២ ៤០០ | ១២ ០០០ |
| | ៤.ភូមិគ្រឹះផ្ទៃដីតូចជាង ៣០០ម$^{២}$ | ខែ | ២៨ ៤០០ | ៤ ៨០០ | ៣៣ ២០០ | ២៧ ៦០០ | ៤ ៨០០ | ៣២ ៤០០ | ២៤ ០០០ | ៤ ៤០០ | ២៨ ៤០០ |
| | ៥.ភូមិគ្រឹះផ្ទៃដីចាប់ពី៣០០-៦០០ម$^{២}$ | ខែ | ៥៦ ៤០០ | ៧ ២០០ | ៦៣ ៦០០ | ៥០ ០០០ | ៧ ២០០ | ៥៧ ២០០ | ៣៥ ៦០០ | ៦ ៤០០ | ៤២ ០០០ |
| | ៦.ភូមិគ្រឹះផ្ទៃដីធំជាង ៦០០ម$^{២}$ | ខែ | សមាមាត្រ | | | | | | | | |
| II | លំនៅដ្ឋានក្នុងបុរីក្រុងរណប | | | | | | | | | | |
| | ១.ផ្ទះល្វែង | ខែ | ១១ ៦០០ | ២ ០០០ | ១៣ ៦០០ | ១១ ២០០ | ២ ០០០ | ១៣ ២០០ | ៨ ៤០០ | ២ ០០០ | ១០ ៤០០ |
| | ២.វីឡាភ្លោះ | ខែ | ២៧ ២០០ | ៤ ០០០ | ៣១ ២០០ | ២៦ ៨០០ | ៤ ០០០ | ៣០ ៨០០ | ១៩ ២០០ | ៣ ៦០០ | ២២ ៨០០ |
| | ៣.វីឡាទោលផ្ទៃដីតូចជាង៣០០ម$^{២}$ | ខែ | ៣៧ ៦០០ | ៤ ៨០០ | ៤២ ៤០០ | ៣៦ ៨០០ | ៤ ៨០០ | ៤១ ៦០០ | ២៨ ៨០០ | ៤ ៤០០ | ៣៣ ២០០ |
| | ៤.វីឡាទោលផ្ទៃដីចាប់ពី៣០០ម$^{២}$ឡើង | ខែ | សមាមាត្រ | | | | | | | | |
| III | ខុនដូ/អាផាតមិន (គិតចំនួនយូនីត) | | | | | | | | | | |
| | ១.តូចជាង៣បន្ទប់/យូនីត | រ/យូនីត.ខែ | ១៨ ៨០០ | ២ ៤០០ | ២១ ២០០ | ១៨ ៤០០ | ២ ៤០០ | ២០ ៨០០ | ១៨ ៤០០ | ២ ៤០០ | ២០ ៨០០ |
| | ២.ចាប់ពី៣បន្ទប់/យូនីត | រ/យូនីត.ខែ | សមាមាត្រ | | | | | | | | |
| IV | ផ្ទះជួលឱ្យកម្មករ (គិតចំនួនបន្ទប់) | | | | | | | | | | |

| ល.រ | ប្រភេទទីតាំងបង្កើតសំរាម សំណល់រឹងទីប្រជុំជន | ឯកតា | កម្រែអតិបរមានៃសេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | រាជធានីភ្នំពេញ | | | ក្រុង | | | ស្រុក | | |
| | | | សេវាសំអាត ប្រមូល ដឹកជញ្ជូន | សេវាទីលាន | សេវាគ្រប់គ្រង (សរុប) | សេវាសំអាត ប្រមូល ដឹកជញ្ជូន | សេវាទីលាន | សេវាគ្រប់គ្រង (សរុប) | សេវាសំអាត ប្រមូល ដឹកជញ្ជូន | សេវាទីលាន | សេវាគ្រប់គ្រង (សរុប) |
| | ១.ផ្ទះអាគារជួលឱ្យកម្មករស្នាក់នៅ | បន្ទប់.ខែ | ៤ ៨០០ | ១ ៦០០ | ៦ ៤០០ | ៤ ៨០០ | ១ ៦០០ | ៦ ៤០០ | ៤ ០០០ | ១ ៦០០ | ៥ ៦០០ |
| V | ផ្ទះជួលឱ្យបរទេសស្នាក់នៅ | | | | | | | | | | |
| | ១.ផ្ទះជួលអោយបរទេសស្នាក់នៅ | ផ្ទះ | ទ្វេគុណ | | | | | | | | |
| ខ | ទីតាំងអាជីវកម្មទូទៅ | | | | | | | | | | |
| I | ផ្ទះធ្វើអាជីវកម្មទូទៅ | | | | | | | | | | |
| | ១.ទំហំផ្ទះ១ល្វែង | ផ្ទះ | ៤៥ ២០០ | ៦ ០០០ | ៥១ ២០០ | ៤៤ ៤០០ | ៦ ០០០ | ៥០ ៤០០ | ៣៦ ៤០០ | ៤ ៨០០ | ៤១ ២០០ |
| | ២.ទំហំចាប់ពីផ្ទះ២ល្វែងឡើង | ផ្ទះ | សមាមាត្រ | | | | | | | | |
| II | ឱសថស្ថាន | | | | | | | | | | |
| | ១.ទំហំផ្ទះ១ល្វែង | ផ្ទះ | ៤៥ ២០០ | ៦ ០០០ | ៥១ ២០០ | ៤៤ ៤០០ | ៦ ០០០ | ៥០ ៤០០ | ៣៦ ៤០០ | ៤ ៨០០ | ៤១ ២០០ |
| | ២.ទំហំចាប់ពីផ្ទះ២ល្វែងឡើង | ផ្ទះ | សមាមាត្រ | | | | | | | | |
| III | ភោជនីយដ្ឋាន/អាហារដ្ឋាន | | | | | | | | | | |
| | ១.អាហារដ្ឋានផ្ទះ១ល្វែង (១ជាន់) | ផ្ទះ | ៦២ ០០០ | ៨ ០០០ | ៧០ ០០០ | ៦០ ៨០០ | ៨ ០០០ | ៦៨ ៨០០ | ៥៩ ៦០០ | ៨ ០០០ | ៦៧ ៦០០ |
| | ២.ភោជនីយដ្ឋានផ្ទះ១ល្វែង (១ជាន់) | ផ្ទះ | ១០៣ ២០០ | ១៣ ២០០ | ១១៦ ៤០០ | ១០១ ២០០ | ១៣ ២០០ | ១១៤ ៤០០ | ៩៩ ៦០០ | ១៣ ២០០ | ១១២ ៨០០ |
| | ៣.ភោជនីយដ្ឋាន/អាហារដ្ឋានធំជាង១ល្វែង | ផ្ទះ | សមាមាត្រ | | | | | | | | |
| | ៤.ភោជនីយដ្ឋានប៊ូហ្វេ (គិតផ្ទៃអគារ) | ម២.ខែ | ២ ០០០ | ៤០០ | ២ ៤០០ | ២ ០០០ | ៤០០ | ២ ៤០០ | ២ ០០០ | ៤០០ | ២ ៤០០ |
| គ | សណ្ឋាគារនិងផ្ទះសំណាក់ | | | | | | | | | | |
| I | បឹងហ្គាឡូ (គិតចំនួនបន្ទប់) | | | | | | | | | | |
| | ១.បឹងហ្គាឡូ | បន្ទប់.ខែ | ៣០ ០០០ | ៤ ០០០ | ៣៤ ០០០ | ២៩ ៦០០ | ៤ ០០០ | ៣៣ ៦០០ | ២៩ ២០០ | ៤ ០០០ | ៣៣ ២០០ |
| II | សណ្ឋាគារ (គិតចំនួនបន្ទប់) | | | | | | | | | | |
| | ១.មានអាហារដ្ឋាន | បន្ទប់.ខែ | ២២ ៨០០ | ៣ ២០០ | ២៦ ០០០ | ២២ ៤០០ | ៣ ២០០ | ២៥ ៦០០ | ២២ ០០០ | ៣ ២០០ | ២៥ ២០០ |
| | ២.គ្មានអាហារដ្ឋាន | បន្ទប់.ខែ | ១១ ៦០០ | ១ ៦០០ | ១៣ ២០០ | ១១ ២០០ | ១ ៦០០ | ១២ ៨០០ | ១១ ២០០ | ១ ៦០០ | ១២ ៨០០ |
| III | ផ្ទះសំណាក់ (គិតចំនួនបន្ទប់) | | | | | | | | | | |
| | ១.ផ្ទះសំណាក់ | បន្ទប់.ខែ | ៨ ៨០០ | ១ ២០០ | ១០ ០០០ | ៨ ៤០០ | ១ ២០០ | ៩ ៦០០ | ៨ ៤០០ | ១ ២០០ | ៩ ៦០០ |

| ល.រ | ប្រភេទទីតាំងបង្កើតសំរាម សំណល់រឹងទីប្រជុំជន | ឯកតា | កម្រៃអតិបរមានៃសេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | រាជធានីភ្នំពេញ | | | ក្រុង | | | ស្រុក | | |
| | | | សេវាសំអាត ប្រមូល ដឹកជញ្ជូន | សេវាទីលាន | សេវាគ្រប់គ្រង (សរុប) | សេវាសំអាត ប្រមូល ដឹកជញ្ជូន | សេវាទីលាន | សេវាគ្រប់គ្រង (សរុប) | សេវាសំអាត ប្រមូល ដឹកជញ្ជូន | សេវាទីលាន | សេវាគ្រប់គ្រង (សរុប) |
| ឃ | មណ្ឌលកំសាន្ត | | | | | | | | | | |
| I | រង្គសាល-ក្លឹប (គិតផ្ទៃអគារ) | | | | | | | | | | |
| | ១.ទំហំតូចជាង ២០០ម² | ខែ | ៥៦១ ៦០០ | ៣៦ ០០០ | ៥៩៧ ៦០០ | ៥៥១ ៦០០ | ៣៦ ០០០ | ៥៨៧ ៦០០ | ៥៤១ ៦០០ | ៣៦ ០០០ | ៥៧៧ ៦០០ |
| | ២.ទំហំចាប់ពី២០០-៤០០ ម² | ខែ | ១ ១២៣ ២០០ | ៧២ ០០០ | ១ ១៩៥ ២០០ | ១ ១០៣ ២០០ | ៧២ ០០០ | ១ ១៧៥ ២០០ | ១ ០៨៣ ២០០ | ៧២ ០០០ | ១ ១៥៥ ២០០ |
| | ៣.ទំហំធំជាង ៤០០ម² | ម².ខែ | ៣ ២០០ | ៤០០ | ៣ ៦០០ | ៣ ២០០ | ៤០០ | ៣ ៦០០ | ៣ ២០០ | ៤០០ | ៣ ៦០០ |
| II | KTV (គិតចំនួនបន្ទប់) | | | | | | | | | | |
| | ១.KTV | បន្ទប់.ខែ | ៥២ ៨០០ | ៣ ៦០០ | ៥៦ ៤០០ | ៥១ ៦០០ | ៣ ៦០០ | ៥៥ ២០០ | ៥០ ៨០០ | ៣ ៦០០ | ៥៤ ៤០០ |
| III | បៀរហ្គាឌិន/សាច់អាំង | | | | | | | | | | |
| | ១.ចំណុះតិចជាង ១៥តុ | ខែ | ២៣២ ០០០ | ១៥ ២០០ | ២៤៧ ២០០ | ២២៧ ៦០០ | ១៥ ២០០ | ២៤២ ៨០០ | ២២៣ ៦០០ | ១៥ ២០០ | ២៣៨ ៨០០ |
| | ២.ចំណុះចាប់ពី ១៥-៣០តុ | ខែ | ៤៦៣ ៦០០ | ៣០ ០០០ | ៤៩៣ ៦០០ | ៤៥៥ ២០០ | ៣០ ០០០ | ៤៨៥ ២០០ | ៤៤៦ ៨០០ | ៣០ ០០០ | ៤៧៦ ៨០០ |
| | ៣.ចំណុះធំជាង ៣០តុ | ខែ | សមាមាត្រ | | | | | | | | |
| IV | មហោស្រពរោងភាពយន្ត | | | | | | | | | | |
| | ១.ចំណុះតិចជាង ២០០នាក់ | ខែ | ៣៧៤ ៤០០ | ៤៨ ០០០ | ៤២២ ៤០០ | ៣៦៨ ០០០ | ៤៨ ០០០ | ៤១៦ ០០០ | ៣៦១ ២០០ | ៤៨ ០០០ | ៤០៩ ២០០ |
| | ២.ចំណុះចាប់ពី២០០-៤០០នាក់ | ខែ | ៧៤៨ ៨០០ | ៩៦ ០០០ | ៨៤៤ ៨០០ | ៧៣៥ ៦០០ | ៩៦ ០០០ | ៨៣១ ៦០០ | ៧២២ ០០០ | ៩៦ ០០០ | ៨១៨ ០០០ |
| | ៣.ចំណុះធំជាង ៤០០នាក់ (គិតចំនួនកៅអី) | កៅអី.ខែ | ៣ ២០០ | ៤០០ | ៣ ៦០០ | ២ ៨០០ | ៤០០ | ៣ ២០០ | ២ ៨០០ | ៤០០ | ៣ ២០០ |
| V | កាស៊ីណូ (មិនគិតបញ្ចូលភោជនីយដ្ឋាន ក្លឹបកំសាន្តផ្សេងៗ) | | | | | | | | | | |
| | ១.ចំណុះតិចជាង២០០នាក់ | ខែ | ២ ៩៥៥ ២០០ | ១៩២ ០០០ | ៣ ១៤៧ ២០០ | ២ ៩៤១ ៦០០ | ១៩២ ០០០ | ៣ ១៣៣ ៦០០ | ២ ៨៨៨ ០០០ | ១៩២ ០០០ | ៣ ០៨០ ០០០ |
| | ២.ចំណុះចាប់ពី២០០-៤០០នាក់ | ខែ | ៥ ៩៩០ ៤០០ | ៣៨៤ ០០០ | ៦ ៣៧៤ ៤០០ | ៥ ៨៨៣ ២០០ | ៣៨៤ ០០០ | ៦ ២៦៧ ២០០ | ៥ ៧៧៥ ៦០០ | ៣៨៤ ០០០ | ៦ ១៥៩ ៦០០ |
| | ៣.ចំណុះលើសពី៤០០នាក់ឡើង | ខែ | សមាមាត្រ | | | | | | | | |
| ង | មជ្ឈមណ្ឌលពាណិជ្ជកម្ម/លក់ដូរ | | | | | | | | | | |
| I | ផ្សារទំនើប (គិតផ្ទៃអគារ) | | | | | | | | | | |
| | ១.អាគារលក់ទំនិញ/ផ្សារទំនើប | ម².ខែ | ២ ៤០០ | ៤០០ | ២ ៨០០ | ២ ៤០០ | ៤០០ | ២ ៨០០ | ២ ៤០០ | ៤០០ | ២ ៨០០ |
| II | ផ្សារលក់ដូរធម្មតា (គិតផ្ទៃទីតាំងលក់ដូរ) | | | | | | | | | | |

| ល.រ | ប្រភេទទីតាំងបង្កើតសំរាម សំណល់រឹងទីប្រជុំជន | ឯកតា | កម្រៃអតិបរមានៃសេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | រាជធានីភ្នំពេញ | | | ក្រុង | | | ស្រុក | | |
| | | | សេវាសំអាត ប្រមូល ដឹកជញ្ជូន | សេវាទីលាន | សេវាគ្រប់គ្រង (សរុប) | សេវាសំអាត ប្រមូល ដឹកជញ្ជូន | សេវាទីលាន | សេវាគ្រប់គ្រង (សរុប) | សេវាសំអាត ប្រមូល ដឹកជញ្ជូន | សេវាទីលាន | សេវាគ្រប់គ្រង (សរុប) |
| | ១.ផ្សារ | រៀល/ម៉ែ.ខែ | ២ ០០០ | ៤០០ | ២ ៤០០ | ២ ០០០ | ៤០០ | ២ ៤០០ | ២ ០០០ | ៤០០ | ២ ៤០០ |
| III | ហាងទំនិញ (គិតផ្ទៃអគារ) | | | | | | | | | | |
| | ១.ហាងទំនិញធម្មតា | រៀល/ម៉ែ.ខែ | ១ ២០០ | ៤០០ | ១ ៦០០ | ១ ២០០ | ៤០០ | ១ ៦០០ | ១ ២០០ | ៤០០ | ១ ៦០០ |
| | ២.មីនីម៉ាត | រៀល/ម៉ែ.ខែ | ១ ២០០ | ៤០០ | ១ ៦០០ | ១ ២០០ | ៤០០ | ១ ៦០០ | ១ ២០០ | ៤០០ | ១ ៦០០ |
| IV | អាគារពាណិជ្ជកម្ម (គិតផ្ទៃអគារ) | | | | | | | | | | |
| | ១.អាគារពាណិជ្ជកម្ម | រៀល/ម៉ែ.ខែ | ១ ៦០០ | ៤០០ | ២ ០០០ | ១ ៦០០ | ៤០០ | ២ ០០០ | ១ ៦០០ | ៤០០ | ២ ០០០ |
| ប | មន្ទីរពេទ្យ/សុខភាពឯកជន-ស្វយ័ត | | | | | | | | | | |
| I | មន្ទីរពេទ្យ (គិតចំនួនគ្រែ) | | | | | | | | | | |
| | ១.មន្ទីរពេទ្យ | រៀល/គ្រែ.ខែ | ១៧ ២០០ | ២ ៤០០ | ១៩ ៦០០ | ១៦ ៨០០ | ២ ៤០០ | ១៩ ២០០ | ១៦ ៤០០ | ២ ៤០០ | ១៨ ៨០០ |
| II | មន្ទីរសម្ភព (គិតចំនួនគ្រែ) | | | | | | | | | | |
| | ១.មន្ទីរសម្ភព | រៀល/គ្រែ.ខែ | ១៧ ២០០ | ២ ៤០០ | ១៩ ៦០០ | ១៦ ៨០០ | ២ ៤០០ | ១៩ ២០០ | ១៦ ៤០០ | ២ ៤០០ | ១៨ ៨០០ |
| III | មន្ទីរសំរាកព្យាបាលជំងឺ (គិតចំនួនគ្រែ) | | | | | | | | | | |
| | ១.មន្ទីរសំរាកព្យាបាលជំងឺ | រៀល/គ្រែ.ខែ | ១១ ៦០០ | ១ ៦០០ | ១៣ ២០០ | ១១ ២០០ | ១ ៦០០ | ១២ ៨០០ | ១១ ២០០ | ១ ៦០០ | ១២ ៨០០ |
| IV | បន្ទប់ពិគ្រោះជំងឺ | | | | | | | | | | |
| | ១.បន្ទប់ពិគ្រោះជំងឺ | រៀល/ខែ | ៣០ ០០០ | ៤ ០០០ | ៣៤ ០០០ | ២៩ ៦០០ | ៤ ០០០ | ៣៣ ៦០០ | ២៩ ២០០ | ៤ ០០០ | ៣៣ ២០០ |
| ច | គ្រឹះស្ថានអប់រំឯកជន-ស្វយ័តអង្គការ | | | | | | | | | | |
| I | សាកលវិទ្យាល័យ | | | | | | | | | | |
| | ១.តិចជាង ១០បន្ទប់ | រៀល/ខែ | ២៥២ ៨០០ | ៥៤ ០០០ | ៣០៦ ៨០០ | ២៤៨ ៤០០ | ៥៤ ០០០ | ៣០២ ៤០០ | ១៩៥ ២០០ | ៤៣ ២០០ | ២៣៨ ៤០០ |
| | ២.ចាប់ពី១០-៣០បន្ទប់ | រៀល/ខែ | ៧៥៨ ៤០០ | ១៦២ ០០០ | ៩២០ ៤០០ | ៧៤៤ ៨០០ | ១៦២ ០០០ | ៩០៦ ៨០០ | ៥៨៤ ៨០០ | ១២៩ ៦០០ | ៧១៤ ៤០០ |
| | ៣.ច្រើនជាង ៣០បន្ទប់ | រៀល/ខែ | សមាមាត្រ | | | | | | | | |
| II | សាលារៀនចំណេះទូទៅ | | | | | | | | | | |
| | ១.តិចជាង ១០បន្ទប់ | រៀល/ខែ | ១៦៨ ៨០០ | ៣៦ ០០០ | ២០៤ ៨០០ | ១៦៥ ៦០០ | ៣៦ ០០០ | ២០១ ៦០០ | ១៣០ ០០០ | ២៨ ៨០០ | ១៥៨ ៨០០ |
| | ២.ចាប់ពី១០-៣០បន្ទប់ | រៀល/ខែ | ៥០៥ ៦០០ | ១០៨ ០០០ | ៦១៣ ៦០០ | ៤៩៦ ៤០០ | ១០៨ ០០០ | ៦០៤ ៤០០ | ៣៩០ ០០០ | ៨៦ ៤០០ | ៤៧៦ ៤០០ |

ai ហ.

| ល.រ | ប្រភេទទីតាំងបង្កើតសំរាម សំណល់រឹងទីប្រជុំជន | ឯកតា | កម្រៃអតិបរមានៃសេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | រាជធានីភ្នំពេញ | | | ក្រុង | | | ស្រុក | | |
| | | | សេវាសំអាត ប្រមូល ដឹកជញ្ជូន | សេវាទីលាន | សេវាគ្រប់គ្រង (សរុប) | សេវាសំអាត ប្រមូល ដឹកជញ្ជូន | សេវាទីលាន | សេវាគ្រប់គ្រង (សរុប) | សេវាសំអាត ប្រមូល ដឹកជញ្ជូន | សេវាទីលាន | សេវាគ្រប់គ្រង (សរុប) |
| | ៣.ច្រើនជាង៣០បន្ទប់ | អ៉ិន | សមាមាត្រ | | | | | | | | |
| II | សាលាអង្គការមិនយកថ្លៃសិក្សា | | | | | | | | | | |
| | ១.តិចជាង១០បន្ទប់ | អ៉ិន | ១២៦ ៤០០ | ២៧ ២០០ | ១៥៣ ៦០០ | ១២៤ ៤០០ | ២៧ ២០០ | ១៥១ ៦០០ | ៩៧ ៦០០ | ២១ ៦០០ | ១១៩ ២០០ |
| | ២.ចាប់ពី១០បន្ទប់ឡើង | អ៉ិន | សមាមាត្រ | | | | | | | | |
| III | សាលារៀនកម្រិតអន្តរជាតិ | | | | | | | | | | |
| | ១.តិចជាង១០ បន្ទប់ | អ៉ិន | ៦៣២ ០០០ | ៥៤ ០០០ | ៦៨៦ ០០០ | ៦២០ ៨០០ | ៥៤ ០០០ | ៦៧៤ ៨០០ | ៤៨៧ ៦០០ | ៤៣ ២០០ | ៥៣០ ៨០០ |
| | ២.ចាប់ពី ១០-២០បន្ទប់ | អ៉ិន | ១ ២៦៣ ៦០០ | ១០៨ ០០០ | ១ ៣៧១ ៦០០ | ១ ២៤១ ២០០ | ១០៨ ០០០ | ១ ៣៤៩ ២០០ | ៩៧៤ ៨០០ | ៨៦ ៤០០ | ១ ០៦១ ២០០ |
| | ៣.ច្រើនជាង២០បន្ទប់ | អ៉ិន | សមាមាត្រ | | | | | | | | |
| ជ | គ្រឹះស្ថានអប់រំផ្សេង | | | | | | | | | | |
| I | សាលាចំណេះទូទៅ | | | | | | | | | | |
| | ១.សាលាចំណេះទៅ | អ៉ិន | ២៨០ ៨០០ | ៧២ ០០០ | ៣៥២ ៨០០ | ២៧៦ ០០០ | ៧២ ០០០ | ៣៤៨ ០០០ | ២១៦ ៨០០ | ៥៧ ៦០០ | ២៧៤ ៤០០ |
| ឈ | ក្រុមហ៊ុនឯកជន | | | | | | | | | | |
| I | ក្រុមហ៊ុនឯកជនទូទៅ | | | | | | | | | | |
| | ១.បុគ្គលិកតិចជាង១៥នាក់ | អ៉ិន | ១៣៣ ៦០០ | ៨ ៨០០ | ១៤២ ៤០០ | ១៣១ ២០០ | ៨ ៨០០ | ១៤០ ០០០ | ១២៨ ៨០០ | ៨ ៨០០ | ១៣៧ ៦០០ |
| | ២.បុគ្គលិកចាប់ពី១៥-៥០នាក់ | អ៉ិន | ៤៤៤ ៨០០ | ២៨ ៨០០ | ៤៧៣ ៦០០ | ៤៣៦ ៨០០ | ២៨ ៨០០ | ៤៦៥ ៦០០ | ៤២៨ ៨០០ | ២៨ ៨០០ | ៤៥៧ ៦០០ |
| | ៣.បុគ្គលិកលើសពី៥០នាក់ | អ៉ិន | សមាមាត្រ | | | | | | | | |
| II | ធនាគារគ្រឹះស្ថានហិរញ្ញវត្ថុ/មីក្រូហិរញ្ញវត្ថុ | | | | | | | | | | |
| | ១.បុគ្គលិកតិចជាង២៥នាក់ | អ៉ិន | ៣៦២ ៨០០ | ២៣ ៦០០ | ៣៨៦ ៤០០ | ៣៥៦ ៤០០ | ២៣ ៦០០ | ៣៨០ ០០០ | ៣៥០ ០០០ | ២៣ ៦០០ | ៣៧៣ ៦០០ |
| | ២.បុគ្គលិកចាប់ពី២៥-៥០នាក់ | អ៉ិន | ៧២៥ ៦០០ | ៤៦ ៨០០ | ៧៧២ ៤០០ | ៧១២ ៤០០ | ៤៦ ៨០០ | ៧៥៩ ២០០ | ៦៩៩ ៦០០ | ៤៦ ៨០០ | ៧៤៦ ៤០០ |
| | ៣.បុគ្គលិកលើសពី៥០នាក់ | អ៉ិន | សមាមាត្រ | | | | | | | | |
| ៣ | ស្ថានីយ-ដេប៉ូប្រេងឥន្ធនៈ | | | | | | | | | | |
| I | មានកន្លែងលាងរថយន្តឬហាងទំនិញ | អ៉ិន | ៣០៩ ២០០ | ២០ ០០០ | ៣២៩ ២០០ | ៣០៣ ៦០០ | ២០ ០០០ | ៣២៣ ៦០០ | ២៩៨ ០០០ | ២០ ០០០ | ៣១៨ ០០០ |
| II | គ្មានកន្លែងលាងរថយន្តឬហាងទំនិញ | អ៉ិន | ១២៧ ៦០០ | ៨ ៤០០ | ១៣៦ ០០០ | ១២៥ ២០០ | ៨ ៤០០ | ១៣៣ ៦០០ | ១២២ ៨០០ | ៨ ៤០០ | ១៣១ ២០០ |

| ល.រ | ប្រភេទទីតាំងបង្កើតសំរាម សំណល់រឹងទីប្រជុំជន | ឯកតា | កម្រៃអតិបរមានៃសេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | រាជធានីភ្នំពេញ | | | ក្រុង | | | ស្រុក | | |
| | | | សេវាសំអាត ប្រមូល ដឹកជញ្ជូន | សេវាទីលាន | សេវាគ្រប់គ្រង (សរុប) | សេវាសំអាត ប្រមូល ដឹកជញ្ជូន | សេវាទីលាន | សេវាគ្រប់គ្រង (សរុប) | សេវាសំអាត ប្រមូល ដឹកជញ្ជូន | សេវាទីលាន | សេវាគ្រប់គ្រង (សរុប) |
| ដ | ទីតាំងស្តុកផ្ទុះទំនិញ | | | | | | | | | | |
| I | កំពង់ផែ (គិតផ្ទៃដី) | | | | | | | | | | |
| | ១.កំពង់ផែ | ម$^{២}$.ខែ | ៣ ២០០ | ៤០០ | ៣ ៦០០ | ២ ៨០០ | ៤០០ | ៣ ២០០ | ២ ៨០០ | ៤០០ | ៣ ២០០ |
| II | ស្ថានីយរថភ្លើង(គិតផ្ទៃអគារ) | | | | | | | | | | |
| | ១.ស្ថានីយរថភ្លើង | ម$^{២}$.ខែ | ៣ ២០០ | ៤០០ | ៣ ៦០០ | ២ ៨០០ | ៤០០ | ៣ ២០០ | ២ ៨០០ | ៤០០ | ៣ ២០០ |
| III | ចំណតរថយន្តអ្នកដំណើរ(គិតផ្ទៃអគារ) | | | | | | | | | | |
| | ១.ចំណតរថយន្តអ្នកដំណើរ | ម$^{២}$.ខែ | ៣ ២០០ | ៤០០ | ៣ ៦០០ | ២ ៨០០ | ៤០០ | ៣ ២០០ | ២ ៨០០ | ៤០០ | ៣ ២០០ |
| IV | ព្រលានយន្តហោះ (គិតផ្ទៃអគារ) | | | | | | | | | | |
| | ១.ព្រលានយន្តហោះ | ម$^{២}$.ខែ | ៤ ០០០ | ៤០០ | ៤ ៤០០ | ៤ ០០០ | ៤០០ | ៤ ៤០០ | ៤ ០០០ | ៤០០ | ៤ ៤០០ |
| V | ផែស្ងួត (គិតផ្ទៃដី) | | | | | | | | | | |
| | ១.ទំហំតូចជាង ១០០០០ម$^{២}$ | ខែ | ៧៤៨ ៨០០ | ៤៨ ០០០ | ៧៩៦ ៨០០ | ៧៣៥ ៦០០ | ៤៨ ០០០ | ៧៨៣ ៦០០ | ៧២២ ០០០ | ៤៨ ០០០ | ៧៧០ ០០០ |
| | ២.ទំហំចាប់ពី១០០០០-២០០០០ម$^{២}$ | ខែ | ១ ៤៩៧ ៦០០ | ៩៦ ០០០ | ១ ៥៩៣ ៦០០ | ១ ៤៧០ ៨០០ | ៩៦ ០០០ | ១ ៥៦៦ ៨០០ | ១ ៤៤៤ ០០០ | ៩៦ ០០០ | ១ ៥៤០ ០០០ |
| | ៣.ទំហំធំជាង ២០០០០ម$^{២}$ | ម$^{២}$.ខែ | ៨០០ | ៤០០ | ១ ២០០ | ៨០០ | ៤០០ | ១ ២០០ | ៨០០ | ៤០០ | ១ ២០០ |
| VI | ឃ្លាំងស្តុកទំនិញ (គិតផ្ទៃឃ្លាំង) | | | | | | | | | | |
| | ១.ទំហំតូចជាង ៣០០ម$^{២}$ | ខែ | ១១២ ៤០០ | ៧ ២០០ | ១១៩ ៦០០ | ១១០ ៤០០ | ៧ ២០០ | ១១៧ ៦០០ | ១០៨ ៤០០ | ៧ ២០០ | ១១៥ ៦០០ |
| | ២.ទំហំចាប់ពី ៣០០ ដល់៦០០ម$^{២}$ | ខែ | ២២៤ ៨០០ | ១៤ ៤០០ | ២៣៩ ២០០ | ២២០ ៨០០ | ១៤ ៤០០ | ២៣៥ ២០០ | ២១៦ ៨០០ | ១៤ ៤០០ | ២៣១ ២០០ |
| | ៤.ទំហំធំជាង៦០០ម$^{២}$ | ម$^{២}$.ខែ | ៤០០ | ៤០០ | ៨០០ | ៤០០ | ៤០០ | ៨០០ | ៤០០ | ៤០០ | ៨០០ |
| VII | ឃ្លាំងស្តុកប្រេងឥន្ធនៈ | | | | | | | | | | |
| | ១.ពោងស្តុកតិចជាង ៣ | ខែ | ៦៧៤ ០០០ | ៤៣ ២០០ | ៧១៧ ២០០ | ៦៦២ ០០០ | ៤៣ ២០០ | ៧០៥ ២០០ | ៦៥០ ០០០ | ៤៣ ២០០ | ៦៩៣ ២០០ |
| | ២.ពោងស្តុកចាប់ពី ៣-៤ | ខែ | ១ ៣៤៨ ០០០ | ៨៦ ៤០០ | ១ ៤៣៤ ៤០០ | ១ ៣២៤ ០០០ | ៨៦ ៤០០ | ១ ៤១០ ៤០០ | ១ ២៩៩ ៦០០ | ៨៦ ៤០០ | ១ ៣៨៦ ០០០ |
| | ៣.ពោងស្តុកលើសពី ៤ | ខែ | សមាមាត្រ | | | | | | | | |
| VIII | ចំណតរថយន្តដឹកផ្ទុះទំនិញ (គិតផ្ទៃដី) | | | | | | | | | | |
| | ១.ទំហំតូចជាង ៥០០ម$^{២}$ | ខែ | ១៥០ ០០០ | ៩ ៦០០ | ១៥៩ ៦០០ | ១៤៧ ២០០ | ៩ ៦០០ | ១៥៦ ៨០០ | ១៤៤ ៤០០ | ៩ ៦០០ | ១៥៤ ០០០ |

| ល.រ | ប្រភេទទីតាំងបង្កើតសំរាម សំណល់រឹងទីប្រជុំជន | ឯកតា | កម្រៃអតិបរមានៃសេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | រាជធានីភ្នំពេញ | | | ក្រុង | | | ស្រុក | | |
| | | | សេវាសំអាត ប្រមូល ដឹកជញ្ជូន | សេវាទីលាន | សេវាគ្រប់គ្រង (សរុប) | សេវាសំអាត ប្រមូល ដឹកជញ្ជូន | សេវាទីលាន | សេវាគ្រប់គ្រង (សរុប) | សេវាសំអាត ប្រមូល ដឹកជញ្ជូន | សេវាទីលាន | សេវាគ្រប់គ្រង (សរុប) |
| | ២.ទំហំចាប់ពី៥០០-១៥០០ម៉ែ | ខែ | ៤៤៩ ៦០០ | ២៨ ៨០០ | ៤៧៨ ៤០០ | ៤៤១ ៦០០ | ២៨ ៨០០ | ៤៧០ ៤០០ | ៤៣៣ ២០០ | ២៨ ៨០០ | ៤៦២ ០០០ |
| | ៣.ទំហំធំជាង ១៥០០ម៉ែ | ម៉ែ.ខែ | ៤០០ | ៤០០ | ៨០០ | ៤០០ | ៤០០ | ៨០០ | ៤០០ | ៤០០ | ៨០០ |
| IX | អាគារឃ្លាំងលក់រថយន្ត-ម៉ូតូ (គិតផ្ទៃអគារ) | | | | | | | | | | |
| | ១.ទំហំតូចជាង ២០០ម៉ែ | ខែ | ៦៥ ៦០០ | ៤ ៤០០ | ៧០ ០០០ | ៦៤ ៤០០ | ៤ ៤០០ | ៦៨ ៨០០ | ៦៣ ២០០ | ៤ ៤០០ | ៦៧ ៦០០ |
| | ២.ទំហំចាប់ពី២០០-៤០០ម៉ែ | ខែ | ១៣១ ២០០ | ៨ ៤០០ | ១៣៩ ៦០០ | ១២៨ ៨០០ | ៨ ៤០០ | ១៣៧ ២០០ | ១២៦ ៤០០ | ៨ ៤០០ | ១៣៤ ៨០០ |
| | ៣.ទំហំធំជាង ៤០០ម៉ែ | ម៉ែ.ខែ | ៤០០ | ៤០០ | ៨០០ | ៤០០ | ៤០០ | ៨០០ | ៤០០ | ៤០០ | ៨០០ |
| ឋ | រោងចក្រ សិប្បកម្ម | | | | | | | | | | |
| I | រោងចក្រ/ឧស្សាហកម្ម | | | | | | | | | | |
| | ១.កម្មករ/បុគ្គលិកក្រោម២៥០នាក់ | ខែ | ៩៣៦ ០០០ | ៦០ ០០០ | ៩៩៦ ០០០ | ៩១៩ ២០០ | ៦០ ០០០ | ៩៧៩ ២០០ | ៩០២ ៤០០ | ៦០ ០០០ | ៩៦២ ៤០០ |
| | ២.កម្មករ/បុគ្គលិកចាប់ពី២៥០-៥០០នាក់ | ខែ | ១ ៨៧២ ០០០ | ១២០ ០០០ | ១ ៩៩២ ០០០ | ១ ៨៣៨ ៤០០ | ១២០ ០០០ | ១ ៩៥៨ ៤០០ | ១ ៨០៤ ៨០០ | ១២០ ០០០ | ១ ៩២៤ ៨០០ |
| | ៣.បុគ្គលិក/កម្មករលើសពី៥០០នាក់ | ខែ | សមាមាត្រ | | | | | | | | |
| II | សិប្បកម្ម/ឧស្សាហកម្មធុនស្រាល | | | | | | | | | | |
| | ១.បុគ្គលិក/កម្មករក្រោម ៥០នាក់ | ខែ | ១៨៧ ២០០ | ១២ ០០០ | ១៩៩ ២០០ | ១៨៤ ០០០ | ១២ ០០០ | ១៩៦ ០០០ | ១៨០ ៨០០ | ១២ ០០០ | ១៩២ ៨០០ |
| | ២.បុគ្គលិក/កម្មករចាប់ពី ៥០នាក់ | ខែ | សមាមាត្រ | | | | | | | | |
| ឱ | ស្ថានទូត-កុងស៊ុល-អង្គការ | | | | | | | | | | |
| I | ស្ថានទូត-កុងស៊ុល (គិតផ្ទៃដី) | | | | | | | | | | |
| | ១.តូចជាង ១២០០ម៉ែ | ខែ | ៨២៨ ៤០០ | ៥៣ ២០០ | ៨៨១ ៦០០ | | | | | | |
| | ១.ចាប់ពី ១២០០ម៉ែ | ម៉ែ.ខែ | ១ ២០០ | ៤០០ | ១ ៦០០ | | | | | | |
| II | អង្គការមិនមែនរដ្ឋាភិបាល | ខែ | ៤៦៨ ០០០ | ៣០ ០០០ | ៤៩៨ ០០០ | ៣៦៨ ០០០ | ២៤ ០០០ | ៣៩២ ០០០ | ២៧០ ៨០០ | ១៨ ០០០ | ២៨៨ ៨០០ |
| ឍ | ស្ថាប័ន/អង្គភាពរដ្ឋ | | | | | | | | | | |
| I | ក្រសួង ស្ថាប័ន | ខែ | ៧៤៨ ៨០០ | ៩៦ ០០០ | ៨៤៤ ៨០០ | | | | | | |
| II | មន្ទីរ អង្គភាពរដ្ឋ | ខែ | ១១២ ៤០០ | ១៤ ៤០០ | ១២៦ ៨០០ | ៩២ ០០០ | ១២ ០០០ | ១០៤ ០០០ | ៤៥ ២០០ | ៦ ០០០ | ៥១ ២០០ |
| ណ | ផ្សេងៗ | | | | | | | | | | |

| ល.រ | ប្រភេទទីតាំងបង្កើតសំរាម សំណល់រឹងទីប្រជុំជន | ឯកតា | កម្រៃអតិបរមានៃសេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | រាជធានីភ្នំពេញ | | | ក្រុង | | | ស្រុក | | |
| | | | សេវាសំអាត ប្រមូល ដឹកជញ្ជូន | សេវាទីលាន | សេវាគ្រប់គ្រង (សរុប) | សេវាសំអាត ប្រមូល ដឹកជញ្ជូន | សេវាទីលាន | សេវាគ្រប់គ្រង (សរុប) | សេវាសំអាត ប្រមូល ដឹកជញ្ជូន | សេវាទីលាន | សេវាគ្រប់គ្រង (សរុប) |
| I | ការធ្វើកម្មវិធីនៅទីសាធារណៈ: | | | | | | | | | | |
| | ១.កម្មវិធីអ្នកចូលរួមតិចជាង 1000នាក់/ថ្ងៃ | រ/ថ្ងៃ | ៣៧៤ ៤០០ | ២៤ ០០០ | ៣៩៨ ៤០០ | ៣៦៨ ០០០ | ២៤ ០០០ | ៣៩២ ០០០ | ៣៦១ ២០០ | ២៤ ០០០ | ៣៨៥ ២០០ |
| | ២.កម្មវិធីអ្នកចូលរួមចាប់ពី 1000-១៥00នាក់/ថ្ងៃ | រ/ថ្ងៃ | ៥៦១ ៦០០ | ៣៦ ០០០ | ៥៩៧ ៦០០ | ៥៥១ ៦០០ | ៣៦ ០០០ | ៥៨៧ ៦០០ | ៥៤១ ៦០០ | ៣៦ ០០០ | ៥៧៧ ៦០០ |
| | ៣.កម្មវិធីអ្នកចូលរួមលើសពី ១៥00នាក់/ថ្ងៃ | រ/ថ្ងៃ | សមាមាត្រ | | | | | | | | |
| | ៤.ការប្រគុំជន្ត្រីក្នុង១ថ្ងៃ | រ/ថ្ងៃ | ១ ១២៣ ២០០ | ៧២ ០០០ | ១ ១៩៥ ២០០ | ១ ១០៣ ២០០ | ៧២ ០០០ | ១ ១៧៥ ២០០ | ១ ០៨៣ ២០០ | ៧២ ០០០ | ១ ១៥៥ ២០០ |
| II | ការលក់ដូរចល័តតាមដងផ្លូវ (ក្នុង១ថ្ងៃ) | | | | | | | | | | |
| | ១.ការលក់ដូរផ្សេងៗតាមដងផ្លូវ | រ/ថ្ងៃ | ៤០០ | ៤០០ | ៨០០ | ៤០០ | ៤០០ | ៨០០ | ៤០០ | ៤០០ | ៨០០ |
| III | ការដ្ឋានសាងសង់ផ្សេងៗ (គិតបរិមាណ) | | | | | | | | | | |
| | ១.បញ្ចេញសំណល់រឹងចេញពីការដ្ឋានដោយប្រើប្រាស់ក្រុមហ៊ុនផ្តល់ សេវាប្រមូលនិងដឹកជញ្ជូន | រ/តោន | ១៥៦ ០០០ | ២០ ០០០ | ១៧៦ ០០០ | ១៥៣ ២០០ | ២០ ០០០ | ១៧៣ ២០០ | ១៥០ ៤០០ | ២០ ០០០ | ១៧០ ៤០០ |

៧

សំគាល់៖ -ដោយផ្អែកលើប្រភេទនិងកម្រៃអតិបរមា នៃទីតាំងបង្កើតសំរាម សំណល់រឹងទីប្រជុំជនដូចដែលមានចែងក្នុងតារាងខាងលើ រដ្ឋបាលរាជធានី ក្រុង ស្រុក អាចបែងចែកជាកម្រៃសេវាលម្អិតបន្ថែមទៀត សម្រាប់ប្រភេទជាក់ស្តែងនីមួយៗ ។

-កម្រៃសេវាទីលានប្រកបដោយអនាម័យ ២០.០០០ (ពីរម៉ឺន) រៀលក្នុងមួយតោន